ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៤ លេខ ៤១_៤២ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

ក

មាតិកា

I ទីស្តីការគណៈរដ្ឋមន្ត្រី

១—អនុក្រឹត្យ

១៣.១១.៩៦ អនុក្រឹត្យលេខ ១៩៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៧៨៣

១៣.១១.៩៦ អនុក្រឹត្យលេខ ១៩៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៧៨៥

១៣.១១.៩៦ អនុក្រឹត្យលេខ ១៩៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៧៨៦

២— សេចក្តីសំរេច

១៤.១១.៩៦ សេចក្តីសំរេចលេខ ៤៤ សសរ ស្តីពីការបង្កើតគណៈកម្មការដោះស្រាយបញ្ហាជនអនាថាខ្មែរ នៅប្រទេសវៀតណាម ១៧៨៨

II ការងារបណ្តាក្រសួង

១—ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ប្រកាស

០៤.១១.៩៦ ប្រកាសលេខ ៦៦៤ ប្រក.សហវ ស្តីពីការបញ្ជូនលិខិតយុត្តិការភ្ជាប់ជាមួយអាណត្តិបើកប្រាក់ ១៧៩១

២—ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាស

០៤.១១.៩៦ ប្រកាសលេខ ៦២១ ផក.ប្រកអនុញ្ញាតអោយលោក កែវ សុខ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងជាងក្រឡឹង និង ជួសជុលម៉ាស៊ីន ១៧៩៣

០៤.១១.៩៦ ប្រកាសលេខ ៦២២ ផក.ប្រកអនុញ្ញាតអោយលោក សេង គង់ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការផលិតកម្មជួសជុលគ្រឿងអគ្គិសនី និង ក្រូម៉េ ១៧៩៣

០៤.១១.៩៦	ប្រកាសលេខ ៦២៣ ផក.ប្រកអនុញ្ញាតអោយលោក អោ យ៉ាត ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម	១៧៩៤
០៤.១១.៩៦	ប្រកាសលេខ ៦២៤ ផក.ប្រកអនុញ្ញាតអោយលោក ហ៊ល់ រស់ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា ជាម្ចាស់មូលដ្ឋានផលិតកម្មក្រឡឹងនិងស្វដែក ផ្ទេរភារកិច្ចគ្រប់គ្រងជូនអ្នកស្រី លឹម មុំ វិញ	១៧៩៤
០៤.១១.៩៦	ប្រកាសលេខ ៦២៥ ផក.ប្រកអនុញ្ញាតអោយលោក លី ចុល ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឡផលិតឥដ្ឋ ក្បឿង	១៧៩៥
០៤.១១.៩៦	ប្រកាសលេខ ៦២៦ ផក.ប្រកអនុញ្ញាតអោយអ្នកស្រី គាន កែវតារា ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការផលិតស្រាស សញ្ញា "BTB "	១៧៩៥
០៤.១១.៩៦	ប្រកាសលេខ ៦២៧ ផក.ប្រកអនុញ្ញាតអោយអ្នកស្រី សំ គឹមអិន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរសិប្បកម្មកែច្នៃ និង ផលិតជីនីត្រូហ្សូត	១៧៩៦
០៤.១១.៩៦	ប្រកាសលេខ ៦២៨ ផក.ប្រកអនុញ្ញាតអោយលោក សុខ លាង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា ប្តូរទីតាំងចាស់នៃសិប្បកម្មផលិតទឹកស៊ីអ៊ីវ	១៧៩៧
០៤.១១.៩៦	ប្រកាសលេខ ៦២៩ ផក.ប្រកអនុញ្ញាតអោយអ្នកស្រី លាប បួយ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១២០ សេះ	១៧៩៧
៦.១១.៩៦	ប្រកាសលេខ ៦៣៦ ផក.ប្រក អនុញ្ញាតលោកក្រុមហ៊ុន យ៉ុងហ្វបហ៊្វីនីធីរ៍ និង ហ្វីធីរ៍ តំណាងដោយលោក CHEN HSI HSIEN សញ្ជាតិតៃវ៉ាន់ បង្កើតរោងចក្រផលិតគ្រឿងសង្ហារឹម	១៧៩៨

១២.១១.៩៦ ប្រកាសលេខ ៦៣៩ ផក.ប្រក អនុញ្ញាតលោក សៀក ឃាង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការសិប្បកម្មស្ល់ដែក និង កិន ស្ពាន់ ១៧៩៩

៣—ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

០៦.១១.៩៦ ប្រកាសលេខ ៣២២ ពណ.គន.ប្រក ស្តីពីការប្រគល់ទីតាំងឃ្លាំងស្បៀងឫស្សីកែវ ១៨០០

៤—ទីស្តីការរដ្ឋមន្ត្រីក្រសួងព័ត៌មាន

ប្រកាស

០៨.១១.៩៦ ប្រកាសលេខ ២៩៧/៩៦ ពម.ប្រក អនុញ្ញាតជូនលោក កង សៀ[illegible] បើកស្ថានីយ៍ផ្សាយសំលេង FM ៩៩ MHZ និងស្ថានីយ៍ទូរទស្ស[illegible] CANEL ១៣ នៅស្រុកតាខ្មៅ ខេត្តកណ្តាល ១៨០១

០៨.១១.៩៦ ប្រកាសលេខ ២៩៨/៩៦ ពម.ប្រក អនុញ្ញាតជូនលោក សារិន បើកអាជីវកម្មរោងពុម្ពឈ្មោះ ហេង ថៃ ១៨០២

១៥.១១.៩៦ ប្រកាសលេខ ៣០៣/៩៦ ពម.ប្រក អនុញ្ញាតអោយលោក ឈឹម សុវណ្ណ បើកអាជីវកម្មទូរទស្សន៍ខ្សែកាបនៅទីរួមខេត្តបាត់ដំបង ១៨០៤

៥—ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

ប្រកាស

០៤.១១.៩៦ ប្រកាសលេខ ៩១៤ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា «សម្តេចធិញ្ញាណ» «មកជាសាលាបឋមសិក្សា ច័ន្ទ សារុន សម្តេចធិញ្ញាណ » ១៨០៥

០៤.១១.៩៦ ប្រកាសលេខ ៩១៥ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា «ព្រៃជ្រូ» មកជាសាលាបឋមសិក្សា «ហ៊ុន សែន ព្រៃជ្រូ » ១៨០៦

០៤.១១.៩៦	ប្រកាសលេខ ៩១៧ អយក.ប្រក ស្តីពីការប្តូរឈ្មោះវិទ្យាល័យពាមជីកង ទៅជាវិទ្យាល័យ «ហ៊ុន សែន ពាមជីកង» ស្ថិតនៅក្នុងស្រុកកងមាស ខេត្តកំពង់ចាម	១៨០៨
០៤.១១.៩៦	ប្រកាសលេខ ៩១៨ អយក.ប្រក ស្តីពីការប្តូរឈ្មោះវិទ្យាល័យអង្គរជ័យទៅជាវិទ្យាល័យ «សម្តេច ជា ស៊ីម «អង្គរជ័យ» ស្ថិតនៅស្រុកអង្គរជ័យខេត្តកំពត	១៨០៩
០៤.១១.៩៦	ប្រកាសលេខ ៩១៩ អយក.ប្រក ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យខ្ចៅ ទៅជាអនុវិទ្យាល័យ «ហ៊ុន សែន ខ្ចៅ» ស្ថិតក្នុងស្រុកកងមាស ខេត្តកំពង់ចាម	១៨១០
០៤.១១.៩៦	ប្រកាសលេខ ៩២០ អយក.ប្រក ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យព្រែកអាជីទៅជាអនុវិទ្យាល័យ «សម្តេច ហ៊ុន សែន ព្រែកអាជី» ស្ថិត ក្នុងស្រុកក្រូចឆ្មា ខេត្តកំពង់ចាម	១៨១២
០៤.១១.៩៦	ប្រកាសលេខ ៩២១ អយក.ប្រក ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យព្រែកកំពិស ទៅជាអនុវិទ្យាល័យ«សម្តេច ហ៊ុន សែន«ព្រែកកំពិស» ស្ថិតក្នុងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល	១៨១៣
០៤.១១.៩៦	ប្រកាសលេខ ៩២២ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យអូរជ្រៅ ក្នុងស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ	១៨១៥
០៤.១១.៩៦	ប្រកាសលេខ ៩២៣ អយក.ប្រក ស្តីពីការប្តូរឈ្មោះវិទ្យាល័យអង្គរនាម ទៅជាវិទ្យាល័យសម្តេចក្រុមព្រះ និង ព្រះអង្គម្ចាស់ក្សត្រិយ៍នរោត្តមម៉ារីរណឫទ្ធិ ស្ថិតក្នុងស្រុកត្រាំកក់ ខេត្តតាកែវ	១៨១៦
០៨.១១.៩៦	ប្រកាសលេខ ៩៣២ អយក.ប្រក ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យពាមកោះស្នាទៅជាអនុវិទ្យាល័យ ហ៊ុន សែន «ពាមកោះស្នា» ស្ថិតក្នុងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម	១៨១៧

០៨.១១.៩៦ ប្រកាសលេខ ៩៣៣ អយក.ប្រក ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យ
ត្រពាំងឫស្សី ទៅជាអនុវិទ្យាល័យសម្តេច ហ៊ុន សែន «ត្រពាំង
ឫស្សី» ស្ថិតក្នុងស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ១៨១៩
០៨.១១.៩៦ ប្រកាសលេខ ៩៣៤ អយក.ប្រក ស្តីពីការបើកវិទ្យាល័យព្រះ
នរោត្តម រណឫទ្ធិ គន្ធបុប្ផា ក្នុងឃុំជ្រៃវៀន ស្រុកព្រៃឈរ ខេត្ត
កំពង់ចាម ១៨២០
០៨.១១.៩៦ ប្រកាសលេខ ៩៣៥ អយក.ប្រក ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យ
ពាមជីលាំង ទៅជាអនុវិទ្យាល័យសម្តេច ហ៊ុន សែន «ពាមជីលាំង»
ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ១៨២១
០៨.១១.៩៦ ប្រកាសលេខ ៩៣៦ អយក.ប្រក ស្តីពីការផ្ទេរវិទ្យាល័យព្រៃឈរ
ទៅជាអនុវិទ្យាល័យសម្តេច ហ៊ុន សែន «ព្រៃទទឹង» ក្នុងស្រុកព្រៃ
ឈរ ខេត្តកំពង់ចាម ១៨២៣
០៨.១១.៩៦ ប្រកាសលេខ ៩៣៧ អយក.ប្រក ស្តីពីការពង្រីក និងប្តូរឈ្មោះ
អនុវិទ្យាល័យ អូររាំងឪ ទៅជាវិទ្យាល័យ ហ៊ុន សែន «អូររាំងឪ»
ស្ថិតក្នុងស្រុកអូររាំងឪ ខេត្តកំពង់ចាម ១៨២៤
១៣.១១.៩៦ ប្រកាសលេខ ៩៤១ អយក.ប្រក ស្តីពីការពង្រីកអនុវិទ្យាល័យ
គីរីវង់ ទៅជាវិទ្យាល័យ គីរីវង់ ក្នុងស្រុកគីរីវង់ ខេត្តតាកែវ ១៨២៥
១៣.១១.៩៦ ប្រកាសលេខ ៩៤២ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ
សម្តេច ហ៊ុន សែន «ចំការដូង» ក្នុងសង្កាត់ព្រៃធំ ខណ្ឌកែប
ក្រុងកែប ១៨២៧
១៣.១១.៩៦ ប្រកាសលេខ ៩៤៥ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលាបឋម
សិក្សាស្តើងជ័យ មកជាសាលាបឋមសិក្សាព្រះអង្គម្ចាស់ក្សត្រិយ៍
នរោត្តម ម៉ារីរណឫទ្ធិ ស្តើងជ័យ ១៨២៨
១៥.១១.៩៦ ប្រកាសលេខ ៩៥០ អយក.ប្រក ស្តីពីការពង្រីកអនុវិទ្យាល័យជើង
ឆ្នុកទៅជាវិទ្យាល័យជើងឆ្នុក ក្នុងស្រុកបាធាយ ខេត្តកំពង់ចាម ១៨២៩

៦—ទីស្តីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ប្រកាស

១៣.១១.៩៦	ប្រកាសលេខ ៧០ ប្រក.បល ៩៦ ផ្ទេរភារកិច្ចលោក ផុង ឈឹម	១៨៣១

៧_ ទីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ប្រកាស

០៨.១១.៩៦	ប្រកាសលេខ ២១១ ប្រក.វវស.បុ ស្តីពីការជ្រើសរើសពលករ អណ្តែត	១៨៣២

៨_ទីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

០៦.១១.៩៦	ប្រកាសលេខ ១៨២ បទ.ប្រក ស្តីពីការតែងតាំងបតិត្ថាហកៈមន្ទីរ ប្រៃសណីយ៍ និង ទូរគមនាគមន៍ ខេត្តកំពត	១៨៣៣
០៦.១១.៩៦	ប្រកាសលេខ ១៨៣ បទ.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ	១៨៣៥
០៦.១១.៩៦	ប្រកាសលេខ ១៨៤ បទ.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ	១៨៣៧

៩_ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្តីសំរេច

១៣.១១.៩៦	សេចក្តីសំរេចលេខ ៦២៤ សសរ.មស.ក្រខ ស្តីពីការបែងចែកសិស្ស និស្សិតចំនួន ៤៦ នាក់ ដែលទើបបញ្ចប់ការសិក្សាពីក្រៅប្រទេស	១៨៣៩

I - ទីស្តីការគណៈរដ្ឋមន្ត្រី

១_ អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៩៤ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ចាម

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ជូនចំពោះអង្គការអន្តរជាតិ ក្រុមហ៊ុន មន្ទីរ ស្រុក ឃុំ ភូមិ ដែលបានចំណាយថវិកាសំរាប់កសាងសមិទ្ធផលផ្សេងៗ ជាប្រយោជន៍សាធារណៈ នៅក្នុងទឹកដីខេត្តកំពង់ចាម ដូចមានរាយឈ្មោះខាងក្រោម ÷

ក- មេដាយមាសស្ថាបនាជាតិ :

១- អង្គការ A.D.B. ទឹកប្រាក់ ១.៥៤៣.000$US

២– អង្គការកម្មវិធីស្បៀងអាហារពិភពលោក អង្ករ ១៤០.៥៣៨ គ.ក្រ

៣– អង្គការប្រាសាក់ប្រចាំខេត្ត ទឹកប្រាក់ ១៨.៩៨០$US

៤– ធនាគារអភិវឌ្ឍន៍អាស៊ី ទឹកប្រាក់ ៤៦.៧៩០$US

៥– អង្គការមូលនិធិសង្គមព្រះរាជាណាចក្រកម្ពុជា ទឹកប្រាក់ ៦០.០០០$US

៦– ក្រុមហ៊ុនចំការកៅស៊ូចំការអណ្តូង ទឹកប្រាក់ ២០.០០០$US

៧– ក្រុមហ៊ុនចំការកៅស៊ូបឹងកេង ទឹកប្រាក់៣៥០.០០០.០០០រៀល

៨– ប្រជាជនឃុំកោះសូទិន ទឹកប្រាក់ ៤៤.១៧៥.០០០រៀល

ខ– មេដាយ ប្រាក់ស្ថាបនាជាតិ :

១– សមាគមមាតាបិតាសិស្សវិទ្យាល័យព្រះសីហនុទឹកប្រាក់១៤.៦០០.០០០រៀល

២– អ្នកវិស្វករតេតព្រំដែន ទឹកប្រាក់ ៩.៤៧៨ $US

៣– ឃុំរការខ្នុរ ទឹកប្រាក់២៣.៩២៤.៥១៧ រៀល

៤– ព្រះចៅអធិការវត្តដងក្តារ ទឹកប្រាក់១៣.០០០.០០០ រៀល

៥– មន្ត្រីស្រុកមេមត់ ទឹកប្រាក់ ៥.៨៩២ $US

គ– មេដាយ សិរីវឌ្ឍ ស្ថាបនាជាតិ :

១– ប្រជាជនភូមិដីដុះ ទឹកប្រាក់ ៧.០០០.០០០ រៀល

២– មន្ត្រីស្រុកស្ទឹងត្រង់ ទឹកប្រាក់១១.៣៥៦.០០០ រៀល

៣– ប្រជាជនឃុំកំពង់ទ្រាស ទឹកប្រាក់ ៣.០០០.០០០ រៀល

៤– មន្ត្រីស្រុកក្រូចឆ្មារ ទឹកប្រាក់ ៥.៧៥០.០០០ រៀល

៥– ប្រជាជនឃុំមេសរជ្រៃ ទឹកប្រាក់១១.៦៣៣.១០០រៀល

៦– អង្គការយូនីសេហ្វ ទឹកប្រាក់ ៧.៦០៦.៥០០ រៀល

៧– ស្រុកកំពង់ចាម ទឹកប្រាក់ ៤.០៥០.០០០ រៀល

៨– ក្រុមហ៊ុនស្តេឡាអាទ័រ ទឹកប្រាក់ ១.៧៥០ $US

៩– មន្ទីរសង្គមកិច្ចការងារ និង អតីតយុទ្ធជនទឹកប្រាក់ ៤.៤៨០.០០០ រៀល

១០– មន្ទីរឧស្សាហកម្មរ៉ែ និង ថាមពល ទឹកប្រាក់ ២.៨០៥.០០០ រៀល

១១– មន្ទីរប្រៃសណីយ៍ខេត្ត ទឹកប្រាក់ ១.០០០ $US

១២– មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទឹកប្រាក់ ៣.៦២៣.៦០០ រៀល

១៣– ប្រជាជនភូមិមហាខ្ញូង ទឹកប្រាក់ ៤.២៨០.០០០ រៀល

១៤– អង្គការបណ្តុះបណ្តាលតុលាការកម្ពុជា ទឹកប្រាក់ ៥.៧០០.០០០ រៀល

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្ត កំពង់ចាម ត្រូវអនុវត្តតាមអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៩៥ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

- តាមសំណើរបស់អភិបាល ខេត្តស្វាយរៀង

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាសស្ថាបនាជាតិ ជូនលោកឧកញ៉ា **សៅ សេរីមុន្នី** ហៅ **សៅ យ៉ាត់** ដែលបានបរិច្ចាគថវិកាចំនួន ១៥.០០០ $US សំរាប់ជួយសាងសង់អាគារសិក្សាមួយខ្នងមាន ០៣ បន្ទប់ នៅសាលាបឋមសិក្សាស្រម៉ បច្ចុប្បន្នសាលាបឋមសិក្សាសម្តេច **ហ៊ុន សែន** ក្នុងឃុំ បុសមន ស្រុករំដួល ខេត្តស្វាយរៀង ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ឲ្យបានទទួលបានលទ្ធផលល្អ ។

ចុះហត្ថលេខា

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៩៦ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ឆ្នាំង

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ជូនសប្បុរសជន ០៥ រូប ដែលបានបរិច្ចាគទ្រព្យសម្បត្តិផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលផ្សេងៗ នៅក្នុងស្រុករលាប្អៀរ ខេត្ត កំពង់ឆ្នាំង ដូចមានរាយនាមខាងក្រោមនេះ ÷

ក- មេដាយមាសស្ថាបនាជាតិ :

- ព្រះតេជគុណ **សុខ ចាន់** ព្រះអនុគណ ស្រុករលាប្អៀរ បរិច្ចាគទឹកប្រាក់ ៦៥.៤៣៤.៥៤៨ រៀល ។

ខ- មេដាយប្រាក់ស្ថាបនាជាតិ :

- លោក **ម៉ៅ គៀន** និងអ្នកស្រី **លឹម យ៉ុន** នៅសហរដ្ឋអាមេរិក បរិច្ចាគទឹកប្រាក់ ៦.៣០១ ដុល្លារអាមេរិក ។

គ- មេដាយសំរិទ្ធ ស្ថាបនាជាតិ :

១- លោក **ទ័រន់ ម៉ុន** និងអ្នកស្រី **យូ ម៉ូលឌុធ** បរិច្ចាគទឹកប្រាក់ ១.៦៨៨ ដុល្លារអាមេរិក ។

២- ឧបាសក **សួន ប៉េង** និង ឧបាសិកា **សេង ចាវ** បរិច្ចាគទឹកប្រាក់ ១.០០០ ដុល្លារអាមេរិក ។

៣-ឯកឧត្តម **ឡាយ អ៊ីពិសិដ្ឋ** និងលោកជំទាវ បរិច្ចាគទឹកប្រាក់ ១.០០០ ដុល្លារអាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបាន លទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២_សេក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ ៤៤ សសរ.

ស្តីពីការបង្កើតគណៈកម្មការដោះស្រាយ

បញ្ហាជនអនាថាខ្មែរ នៅប្រទេស វៀតណាម

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសភាពការណ៍ចាំបាច់

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការមួយ ដើម្បីដោះស្រាយបញ្ហាជនអនាថាខ្មែរ នៅប្រទេសវៀតណាម មាន សមាសភាពដូចខាងក្រោម ÷

១- ឯកឧត្តម **នូច ការនុន** រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី ជាប្រធាន

២- ឯកឧត្តម **អ៊ឹម ឈុនលឹម** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាអនុប្រធាន

៣- ឯកឧត្តម **ជា ម៉េងឈាង** អនុរដ្ឋលេខាធិការក្រសួងហិរញ្ញវត្ថុ ជាសមាជិក

៤- ឯកឧត្តម **ហ៊ុន ថែម** អនុរដ្ឋលេខាធិការនៃក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ជាសមាជិក

៥- ឯកឧត្តម តំណាងកាកបាទក្រហមកម្ពុជា ជាសមាជិក

៦- ឯកឧត្តម **ឡូយ សុផាត** អភិបាលខេត្តស្វាយរៀង ជាសមាជិក

៧- ឯកឧត្តម **ហែម សារ៉ែម** អគ្គកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំក្រុងហូជីមិញ ជាសមាជិក

ប្រការ ២ : គណៈកម្មការដែលចែងក្នុងប្រការ ១ នេះ មានភារកិច្ច ÷

- ស្រង់ស្ថិតិជនអនាថា ជាប្រជាពលរដ្ឋខ្មែរ ដែលកំពុងស្ថិតក្នុងជំរុំប្រមូលផ្តុំ សុងប៉េរប្រទេសវៀតណាម ។
- ទំនាក់ទំនងជាមួយភាគីវៀតណាម ដើម្បីដឹកជញ្ជូនជនអនាថាទាំងអស់នោះ ត្រឡប់មកដល់ស្រុកកំណើត ។
- ក្តាប់សំណួមពរមូលហេតុ និង ពតិមានផ្សេងៗ ជុំវិញករណីជនអនាថាទាំងអស់នោះ ដែលបានឆ្លងកាត់ព្រំដែនទៅធ្វើការសុំទាន ដល់ទីក្រុងហូជីមិញ ប្រទេសវៀតណាម និង រាយការណ៍លើកវិធានការអនុវត្តថ្វាយ និង ជូនរាជរដ្ឋាភិបាលពិនិត្យសំរេច ។

ប្រការ ៣ : គណៈកម្មការនេះ មានអនុគណៈកម្មការមួយសំរាប់ជំនួយការ ដែលមានសមាសភាព ÷

១- លោក តំណាងក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ប្រធាន
២- លោក តំណាងក្រសួងអភិវឌ្ឍន៍ជនបទ អនុប្រធាន
៣- លោក តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សមាជិក
៤- លោក តំណាងក្រសួង សុខាភិបាល សមាជិក
៥- លោក តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក
៦- លោកជំទាវ តំណាងរដ្ឋលេខាធិការកិច្ចការនារី សមាជិក
៧- លោក តំណាងស្ថាប័នយុវនីតិសម្បទា សមាជិក

ប្រការ ៤ : អនុគណៈកម្មការ ដែលចែងក្នុងប្រការ ៣ នេះមានភារកិច្ច ÷

- រៀបចំទីតាំងផែនការ គ្រោងថវិកាចំណាយ និង សំភារៈផ្សេងៗ សំរាប់ទទួលជនអនាថា ដែលត្រូវដឹកជញ្ជូនត្រឡប់ពីប្រទេសវៀតណាមវិញ ។
- អប់រំ និង ហ្វឹកហ្វឺនមុខវិជ្ជាជីវៈតាមលទ្ធភាពជាក់ស្តែងជូនដល់ជនអនាថាទាំងអស់នោះមុនពេលបញ្ជូនទៅដល់ ឬ ពេលទៅដល់ស្រុកកំណើត ។
- ទំនាក់ទំនងសុំជំនួយពីអង្គការអន្តរជាតិ ប្រទេសជាមិត្ត និង សប្បុរសជននានាសំរាប់ការបណ្តុះបណ្តាល ហ្វឹកហ្វឺនមុខវិជ្ជាជីវៈដល់ជនអនាថា ទាំងអស់នោះសំដៅធានាស្ថេរភាពជីវភាពរស់នៅបានសមស្រប ។
- រាយការណ៍អំពីលទ្ធផលការងាររបស់ខ្លួន តាមដំណាក់កាលនីមួយៗ ជូនគណៈកម្មការដោះស្រាយបញ្ហាជនអនាថាខ្មែរនៅប្រទេសវៀតណាម ។

ប្រការ ៥ : សមាជិកគណៈកម្មការដែលចែងក្នុងប្រការ ១ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីសំរួលការងារ ។

ប្រការ ៦ : សមាជិកអនុគណៈកម្មការ ដែលចែងក្នុងប្រការ ៣ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ អនុគណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ដើម្បីសំរួលការងារ ។

ប្រការ ៧ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គាកបាទក្រហមកម្ពុជា ក្រសួងសង្គម

កិច្ចការងារ និង អតីតយុទ្ធជន បណ្តាក្រសួង រដ្ឋលេខាធិការដ្ឋានដែលពាក់ព័ន្ធ សាលាខេត្តស្វាយរៀង និង ឯកឧត្តម អស់លោកដែលមាននាមក្នុងប្រការ ១ និង ប្រការ ៣ ត្រូវទទួលអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពី ថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

II - ការងារបណ្តាក្រសួង

១—ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៦៦៤ ប្រ.ក.សហវ

ស្តីពីការបញ្ជូនលិខិតយុត្តិការគ្មាប់ជាមួយអណត្តិបើកប្រាក់

* * *

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងគណៈរដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស/រតក/១.០៩៤–៨៣ ចុះថ្ងៃទី ២៤– ១០– ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស/រកម/០១៩៦-១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ០១/នស. ចុះថ្ងៃទី ២៨-១២-១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៥-០៧ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ-ប.ក. ចុះថ្ងៃទី ១៦-១១-១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ

សំរេច

ប្រការ ១ : រាល់លិខិតយុត្តិការដែលបញ្ជូនភ្ជាប់មកជាមួយអាណត្តិបើកប្រាក់ផ្ញើមករតនាគារជាតិ ត្រូវកំណត់យក តែច្បាប់ដើម ដោយពុំអនុញ្ញាតយកច្បាប់ថតចម្លងជាដាច់ខាត ។

ប្រការ ២ : អគ្គនាយក- នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានហិរញ្ញកិច្ច ប្រធានរតនាគារជាតិ និង អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ។

ប្រការ ៣ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ហត្ថលេខានិងត្រា
គាត ឈន់

* * *

២- ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាសលេខ ៦២១ ឧក.ប្រក.ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **កែវ សុខ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០៨៨៤១ ភ.ព. ចុះថ្ងៃទី ០៥_១២_៨៤ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ១៧៥ ផ្លូវលេខ ២១៥ សង្កាត់ផ្សារដើមគរ ខ័ណ្ឌទួលគោក បន្តដំណើរការរោងជាងក្រឡឹងនិងផ្លុសផុលម៉ាស៊ីន នៅក្នុងទីតាំងដូចអាស័យដ្ឋាន ខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៦២២ ឧក.ប្រក.ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **សេង គង់** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២២៤៤៧៧ ភ.ព ចុះថ្ងៃទី ២១-៤-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១ក.ផ្លូវលេខ ២៧៦ សង្កាត់ បឹងកេងកងទី២ ខ័ណ្ឌចំការមន បន្តដំណើរការផលិតកម្មផ្លុសផុលគ្រឿងអគ្គិសនី និង គ្រូម៉េ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតតំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះ ពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៦២៣ ឪក.ប្រក.ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ឆោ ឈាន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០២៩៣៦៣ ភ.ព ចុះថ្ងៃទី ០២–៣–១៩៩២ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២៩៤ អ៊ី០ ផ្លូវព្រះមុនីវង្ស សង្កាត់បឹងកេងកងទី ២ ខ័ណ្ឌចំការមនបន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម នៅក្នុងទីតាំង ផ្ទះថ្មី ផ្លូវលេខ ១០៣ សង្កាត់បឹងកេងកងទី ៣ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៦២៤ ឪក.ប្រក.ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រការ ១ :អនុញ្ញាតអោយលោក **ម៉ិល់ រស់** ជាម្ចាស់មូលដ្ឋានផលិតកម្ម ក្រឡឹង និង ស្វដែក ដែលមាន ទីតាំងដីឡូត៍លេខ ២៤ ផ្លូវលេខ ១៦៧ សង្កាត់ ទួលទំពូង ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ផ្ទេរភារកិច្ច គ្រប់គ្រងជូនអ្នកស្រី **លឹម មុំ** វិញ ។

ប្រការ ២ : ទទួលស្គាល់អ្នកស្រី **លឹម មុំ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៤៣៩៤២ ភ.ព ចុះថ្ងៃទី ២១–០១ –៨៥ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ១១៣ ផ្លូវលេខ ៤៤០ សង្កាត់ ទួលទំពូងទី ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ជាម្ចាស់មូលដ្ឋានផលិតក្រឡឹង និងស្វដែក ដែលមានទីតាំងដូចមានចែងក្នុងប្រការ ១ ។

ប្រការ ៣ : អ្នកស្រី **លឹម មុំ** ត្រូវបន្តដំណើរការផលិតកម្ម អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះតទៅ ។

ប្រការ ៤ : ប្រកាសនេះមានតំលៃក្នុងពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៦២៥ ឧក.ប្រក.ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **លី ថុល** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣៩១២៨២ ក.ណ ចុះថ្ងៃទី ០៩_១១_៩១ អាស័យដ្ឋានបច្ចុប្បន្ន ភូមិក្តីចាស់ ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្តាល បន្តដំណើរការឡផលិតឥដ្ឋ ក្បឿង នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៦២៦ ឧក.ប្រក.ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ឝរុន កែវតារា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៩២៣៦១ ប.ប ចុះថ្ងៃទី ២១–៧–១៩៩០ អាស័យដ្ឋានបច្ចុប្បន្នក្រុមទី ៤ ភូមិ ដំណាក់ហ្លួង ឃុំវត្តគរ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង បើកដំណើរការ «សុរាគារបាត់ដំបង» ផលិតស្រាសសញ្ញា «BTB» នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : អ្នកស្រី **គាន កែវនារា** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផល ស្រាសសញ្ញា«BTB» ស្របតាមគំរូសញ្ញាសំគាល់ ដែលបានដឹកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៦២៧ ឧក.ប្រក.ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **សំ គីមអ៊ន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០១៥៤៤ ក.ព ចុះថ្ងៃទី ២៤-០១-៨៦ អាស័យដ្ឋានបច្ចុប្បន្នភូមិឧសភា ឃុំកំពង់កណ្តាល ស្រុកកំពង់បាយ ខេត្តកំពត បើកដំណើរការសិប្បកម្មកែច្នៃ និង ផលិតជីនិត្រូហ្វស្វាត នៅក្នុងទីតាំង ភូមិ ស្តេចគង់ ឃុំស្តេចគង់ខាងត្បូង ស្រុកបន្ទាយមាស ខេត្តកំពត ។

ប្រការ ២ : អ្នកស្រី **សំ គីមអ៊ន** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលជីនិត្រូហ្វស្វាតសញ្ញា«រូបកណ្តាប់ស្រូវ»ស្របតាមគំរូ សញ្ញាសំគាល់ ដែលបានដឹកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៦២៨ ឧក.ប្រក.ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **សុខ លាង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៩៧៦៣៥ ប.ជ ចុះថ្ងៃទី ១២-៤-៩១ អាស័យដ្ឋានបច្ចុប្បន្ន ភូមិគោរដ្ឋាន ឃុំ អូរអំបិល ស្រុក សេរីសោភ័ណ ខេត្តបន្ទាយមានជ័យ ប្តូរទីតាំងចាស់នៃសិប្បកម្មផលិតទឹកស៊ីអ៊ីវ ក្រុមទី ៥ ភូមិ ៤ សង្កាត់ព្រះពន្លា ទីរួមខេត្ត និងខេត្តបន្ទាយមានជ័យ ទៅទីតាំងថ្មី ក្រុមទី ៥ ភូមិ គោរដ្ឋាន ឃុំ អូរអំបិល ស្រុក សេរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

ប្រការ ២ : លោក **សុខ លាង** ត្រូវបានអនុញ្ញាតអោយបន្តដំណើរការផលិតកម្ម និងផលិតបន្ថែមនូវមុខផលិតផលទឹកម្ទេស សញ្ញា «ភ្នំមាសរូបផ្លែម្ទេសបួន»ទឹកត្រីសញ្ញា «ភ្នំមាសរូបកុកបី»និងទឹកស៊ីអ៊ីវម៉ាហ្គីសញ្ញា «ភ្នំមាសរូបភ្នំមាស» លើមុខផលិតផលទឹកស៊ីអ៊ីវចាស់ សញ្ញា«រូបភ្នំ»និងទឹកស៊ីអ៊ីវសញ្ញា«រូបភ្នំមាស» ស្របតាមគំរូសញ្ញាសំគាល់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្មរ៉ែនិង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៦២៩ ឧក.ប្រក.ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **លាង ចួយ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៩០២២០ ភ.ព ចុះថ្ងៃទី ១១-១០-៩០ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២១៧ ផ្លូវកែវមុនី ក្រុមទី ៤៤ សង្កាត់ ទួលស្វាយព្រៃទី ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១២០សេះ នៅក្នុងទីតាំង ភូមិ ស្មោ ឃុំរកាធំ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ ។

ប្រការ ២ : អ្នកស្រី **លាច ចួយ** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម_អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើស ឬ ច្បាប់បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៦៣៦ ឧក.ប្រក.ចុះថ្ងៃទី កក្កដា ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន យ៉ុងហ្វាហ្វើនិធីរ៍និងហ្វីធីរ៍ (Y0NG FA FURNITURES & FIXTURES C0, LTD) តំណាងដោយលោក CHEN HSI HSIEN សញ្ជាតិតៃវ៉ាន់ ភេទប្រុស អាយុ ៤៦ឆ្នាំ អាស័យដ្ឋាន N° 3626 JINH SHYH ROAD CITY TAIWAN ROC កាន់លិខិតឆ្លងដែន លេខ M 754742S ចុះថ្ងៃទី ១៨_៩_៩២ បង្កើតរោងចក្រផលិតគ្រឿងសង្ហារឹមនិងផលិតផលផ្សេងៗអំពីឈើ ដែលមានឈ្មោះថា **រោងចក្រផលិតគ្រឿងសង្ហារឹមយ៉ុងហ្វា** មានទីតាំងនៅភូមិអង្គត្រកៀត ឃុំ កន្ទោក ស្រុក អង្គស្នួល ខេត្ត កណ្តាល ។

ប្រការ ២ : ការសាងសង់ និង រៀបចំគ្រឿងចក្រត្រូវធ្វើទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្មរ៉ែ និង ថាមពលអោយបានសំរេចក្នុងរយៈពេល ១២ ខែ ដោយរាប់បញ្ចូលទាំងរយៈពេលដំណើរការសាកល្បងផង ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែជូនក្រសួងឧស្សាហកម្មរ៉ែ និងថាមពល អំពីស្ថានភាព ផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផល «គ្រឿងសង្ហារឹម បង្ហាន់ដៃនិង ការ៉ូអំពីឈើ» ទៅតាមគំរូ និង ផ្លាកសញ្ញាដែលតំកល់ទុកនៅក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៥ . វត្ថុធាតុដើមឈើមូល ឬ ឈើអារ ដែលយកមកប្រើប្រាស់គឺត្រូវតែជាឈើស្រប ច្បាប់ ។

ប្រការ ៦ : ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ ល្មើសធូន់ធ្ងរនឹងប្រការណាមួយដែលបានចែង ខាងលើ ប្រកាសនេះនឹង ត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

* * *

ប្រកាសលេខ ៦៣៩ ឧក.ប្រក.ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **សៀវ ឃាង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណ ប័ណ្ណលេខ ៣៥០១៩០ ភ.ព ចុះថ្ងៃទី ២២-៩-៩២ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៦៤ ផ្លូវលេខ ២៥៥ សង្កាត់ បឹងសាឡាង ខ័ណ្ឌ ទួលគោក រាជធានីភ្នំពេញ បើកដំណើរការសិប្បកម្មស្លដែក និង កិនស្ពាន់នៅក្នុងទីតាំង ភូមិថ្មី សង្កាត់ដង្កោ ខ័ណ្ឌ ដង្កោ រាជធានីភ្នំពេញ ។

ប្រការ ២ : លោក **សៀវ ឃាង** ត្រូវចាប់ផ្តើមសាងសង់នូវសិប្បកម្មស្លដែក និង កិនស្ពាន់ របស់ខ្លួនអោយរួចជាស្ថាពរ ក្នុងរយៈពេល ០៦ ខែ យ៉ាងយូរ គិតចាប់តាំងពីថ្ងៃ ដែលបានចុះហត្ថលេខាលើប្រកាសនេះ ។ ហួសរយៈពេលកំណត់ប្រកាសនេះត្រូវ ចាត់ទុកជាមោឃៈ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិ

ល្មើសច្បាប់ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋលេខាធិការ
ហត្ថលេខានិង ត្រា
អ៊ិត ប្រាំង

* * *

៣— ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

ប្រកាស

ភ្នំពេញ,ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៣២២ ពណ.គន.ប្រក

ស្តីពីការប្រគល់ទីតាំងឃ្លាំងស្បៀងឬស៊ីកែវ

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

_បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រ កម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

_បានឃើញកិច្ចសន្យាជួលទីតាំងឃ្លាំងស្បៀងឫស៊ីកែវរបស់ក្រុមហ៊ុនស្បៀងកម្ពុជា ចុះ ថ្ងៃទី ០៣_១០_១៩៩៦ រវាងក្រុមហ៊ុនស្បៀងកម្ពុជានៃក្រសួងពាណិជ្ជកម្ម និងក្រុម ហ៊ុន OWER ACE DEVELOPMENT.LTD តំណាងដោយ DAVID CHONG C.H ជនជាតិហុងកុង និងលោក KIMKANGEAR

ជនជាតិខ្មែរ ។

សម្រេច

ប្រការ ១ :ប្រគល់ការគ្រប់គ្រងទីតាំងឃ្លាំងស្បៀងនៅឫស្សីកែវ ក្នុងនោះរួមមាន: ដីធ្លីនិងឃ្លាំងដូចមានចែងក្នុងប្រការ ០១ នៃកិច្ចសន្យាជូនក្រុមហ៊ុន POWER ACE DEVELOPMENT ។

ប្រការ ២ :ក្រុមហ៊ុន POWER ACE DEVELOPMENT ត្រូវគោរពនិងអនុវត្ត អោយបានល្អតាមរាល់ប្រការដែលមានចែងក្នុងកិច្ចសន្យា ចុះថ្ងៃទី ០៣_១០_១៩៩៦ និងច្បាប់នៃ ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ :ប្រធានមន្ទីរ ប្រធាននាយកដ្ឋានគណនេយ្យ_ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋាន បុគ្គលិក ប្រធានក្រុមហ៊ុនស្បៀងកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះអោយទទួលបានលទ្ធផលល្អប្រសើរ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ចម ប្រសិទ្ធ

* * *

៤— ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រកាសលេខ ២៩៧/៩៦ ពម.ប្រក

អនុញ្ញាតអោយលោក កង សឿន ប្រធានក្រុមហ៊ុន

ឯាយ័នពត៌មាន បើកស្ថានីយ៍វិទ្យុផ្សាយសម្លេង

FM ៩៥ MHZ និងស្ថានីយ៍ទូរទស្សន៍ Canal ១៣

រដ្ឋមន្ត្រីក្រសួងពត៌មាន

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១_១១_១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
– បានឃើញព្រះរាជក្រមន.ស.រ.ក.ម ចុះថ្ងៃទី ២៤_០១_១៩៩៦ ច្បាប់ស្តីពីការបង្កើតក្រសួងពតិមាន
– យោងលិខិតស្នើសុំអនុញ្ញាតបើកស្ថានីយវិទ្យុ ទូរទស្សន៍បាយ័ននៅខេត្តកណ្តាល លេខ ០១ ប.ព ចុះថ្ងៃទី ២១_១០_១៩៩៦ របស់លោក **កខ សៀវ**

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **កខ សៀវ** ប្រធានក្រុមហ៊ុនបាយ័នពតិមាន បើកស្ថានីយវិទ្យុផ្សាយសម្លេង FM - 95 Mhz និងស្ថានីយទូរទស្សន៍ Canal 13 ដែលមានកំលាំង ផ្សាយតិចជាង ឬ អតិបរិមា 10 Kw និងកំពស់អង់តែនត្រឹមតែ 120 ៣ ហើយមាន ទីតាំងនៅភូមិតាខ្មៅ ឃុំតាខ្មៅ ស្រុកតាខ្មៅខេត្តកណ្តាល ។

ប្រការ ២ : រាល់ដំណើរការផ្សព្វផ្សាយរបស់ស្ថានីយវិទ្យុទូរទស្សន៍នេះ ត្រូវគោរពនិងអនុវត្តតាមកិច្ចសន្យា និងច្បាប់បញ្ញត្តិ បទបញ្ជា ឬ សេចក្តីណែនាំខាងផ្នែកសោត ទស្សន៍ទាំងឡាយនៃព្រះរាជា ណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីមិនគោរពតាមកិច្ចសន្យាសាមីខ្លួន ត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាននៃព្រះ រាជាណាចក្រកម្ពុជា ។

ប្រការ ៤ : អគ្គនាយកដ្ឋានវិទ្យុ – ទូរទស្សន៍ជាតិកម្ពុជា_នាយកដ្ឋានគ្រប់គ្រងការ បោះ ពុម្ពផ្សាយសោតទស្សន៍នៃអគ្គនាយកដ្ឋានរដ្ឋបាល_ហិរញ្ញវត្ថុ មន្ទីរពតិមានខេត្តកណ្តាល អាជ្ញាធរដែលមានការពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលអនុវត្តតាមប្រកាសនេះតាមភារកិច្ចរៀង ៗ ខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានអនុភាពតតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រកាសលេខ ២៩៤/៩៦ ពម.ប្រក

អនុញ្ញាតជូនលោក សា រិន បើកអាជីវកម្ម

រោងពុម្ពដែលមានឈ្មោះ ហោង ថៃ

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រមលេខ ន.ស.រ.ក.ម .១០.៩៦.១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពតិមាន
- យោងលិខិតជូនដំណឹងរបស់ក្រសួងពតិមានលេខ ១២២៤/៩៤ ពម ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ស្តីពីការបោះពុម្ពផ្សាយ
- យោងលិខិតស្នើសុំអនុញ្ញាតច្បាប់ បើកអាជីវកម្មរោងពុម្ពឈ្មោះ ហោង ថៃ របស់លោក សា រិន ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ :អនុញ្ញាតជូនលោក **សា រិន** ទីលំនៅផ្ទះលេខ ០៨ E_1 ផ្លូវលេខ ១៦៨ សង្កាត់អូរឫស្សី ១ ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ បើកអាជីវកម្មរោងពុម្ពដែលមានឈ្មោះ **ហោង ថៃ** ទីតាំងស្ថិតនៅផ្ទះលេខ ១៥៤ BE_0 ផ្លូវលេខ ១៦១ ក្រុមទី ៣២ សង្កាត់អូរឫស្សី ២ ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ ។

ប្រការ ២ :រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវអនុវត្តតាមកិច្ចសន្យា សមស្របទៅនឹង ទំនៀមទំលាប់សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ :ក្នុងករណីប្រព្រឹត្តិល្មើស ដូចមានចែងក្នុងប្រការ ២សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន ។

ប្រការ ៤ : ប្រធាននាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ សោតទស្សន៍ នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និងប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តតាមប្រកាសនេះតាមភារកិច្ចរៀង ៗ ខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានអនុភាពពតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

ប្រកាសលេខ ៣០៣/៩៦ ពម.ប្រក

អនុញ្ញាតជូនលោក ឈឹម សុវណ្ណ បើកអាជីវកម្ម

ទូរទស្សន៍ខ្សែកាបនៅទីរួមខេត្តបាត់ដំបង

រដ្ឋមន្ត្រីក្រសួងពត៌មាន

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាចុះថ្ងៃទី ០១_១១_១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីប្រកាសលេខ ៧៣១_៩៤ ពម ចុះថ្ងៃទី ៣០_៧_១៩៩៤ របស់ក្រសួងពត៌មាន
- យោងលិខិតសំណើសុំផ្ទេរសិទ្ធិគ្រប់គ្រងអាជីវកម្ម ទូរទស្សន៍ខ្សែកាបជូនទៅលោក **ឈឹម សុវណ្ណ** ចុះថ្ងៃទី ០៧_១១_១៩៩៦ របស់លោក **គីម ចាន់ណា**
- យោងលិខិតលេខ ១៧៤២ ខបម ចុះថ្ងៃទី ០៧_១១_១៩៩៦ របស់សាលាខេត្តបាត់ដំបង

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **ឈឹម សុវណ្ណ** ជនជាតិខ្មែរ ស្ថិតនៅផ្ទះលេខ ១០២/១១ ក្រុម ទី ៣៧ ភូមិ ២០ ឧសភា ឃុំស្វាយប៉ោ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបងបើកអាជីវកម្ម ទូរទស្សន៍ខ្សែកាប សំរាប់បន្តជាវអោយអតិថិជននៅទីរួមខេត្តបាត់

ដំបង ។

ប្រការ ២ :សាមីខ្លួនត្រូវអនុវត្តអោយបានសមស្របតាមគោលការណ៍ ច្បាប់រដ្ឋកំណត់និងទទួលការ ណែនាំផ្ទាល់ពីមន្ទីរពត៌មានខេត្តបាត់ដំបង ។ ត្រូវគោរពតាមកិច្ចសន្យា និងលក្ខន្តិកៈ ហើយហាមប្រើប្រាស់ប្រព័ន្ធនេះ ដើម្បីធ្វើនយោបាយ ឬ ពាណិជ្ជកម្មណាដែលផ្ទុយនឹងច្បាប់រដ្ឋ ។

ប្រការ ៣ :ក្នុងករណីប្រព្រឹត្តល្មើសដូចមានចែងក្នុងប្រការ ២ សាមីខ្លួននឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ :នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយនិងសោតទស្សន៍ នៃអគ្គនាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុ មន្ទីរពត៌មានខេត្តបាត់ដំបង និអាជ្ញាធរពាក់ព័ន្ធ ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀង ៗ ខ្លួន ។

ប្រការ ៥ :ប្រកាសនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខានិងត្រា
អៀង មូលី

* * *

៥— ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

ប្រកាស

ភ្នំពេញ,ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៩១៤ អយក.ប្រក

ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា « សម្តេចពិញ្ញាណ »មកជាសាលាបឋមសិក្សា « ចំនួសារុន_សម្តេចពិញ្ញាណ »

_បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ

មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១_១១_១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

_បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០_៧_១៩៩៤

_បានឃើញព្រះរាជក្រឹត្យលេខ សទ.រកត.០៧៩៦_៥២ ចុះថ្ងៃទី ២៦_៧_១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ ឆ្នាំ

_បានពិនិត្យលិខិតស្នើសុំរបស់ប្រធានមន្ទីរអប់រំយុវជន និងកីឡាខេត្តតាកែវលេខ ៣២៤៩ អយក.ត ចុះថ្ងៃទី ១២ កញ្ញា ១៩៩៦

_តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ :អនុញ្ញាតអោយមន្ទីរអប់រំយុវជន និង កីឡាខេត្តតាកែវ ប្តូរឈ្មោះសាលាបឋម សិក្សា « សម្តោធិញ្ញាណ » ស្ថិតក្នុងភូមិតាស្វ ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវមកជាសាលាបឋមសិក្សា «ច័ន្ទសារុន_សម្តោធិញ្ញាណ » វិញចាប់ពីឆ្នាំ សិក្សា ១៩៩៦_១៩៩៧ នេះតទៅ ។

ប្រការ ២ :បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវបាត់ ទុកជានិរាករណ៍។

ប្រការ ៣ :ប្រធានមន្ទីរក្រសួងអប់រំយុវជន និង កីឡា ប្រធាននាយកដ្ឋានបាត់តាំង ប្រធាននាយកដ្ឋានផែនការ_ហិរញ្ញកិច្ចប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំយុវជន និង កីឡាខេត្តតាកែវ ប្រធានការិយាល័យអប់រំយុវជន និង កីឡា ស្រុក បាទី នាយកសាលាបឋមសិក្សា « ច័ន្ទសារុន_សម្តោធិញ្ញាណ » មានភារកិច្ចអនុវត្ត ប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

គា សាឃាន

* * *

ភ្នំពេញ,ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៩១៥ អយក. ប្រក

ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា

« ហ៊ុន សែន » ព្រៃជ្វរ

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១_១១_១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០_៧_១៩៩៤
- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០_១១_១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ
- បានពិនិត្យលិខិតស្នើសុំរបស់មន្ទីរអប់រំយុវជន និង កីឡា ខេត្តតាកែវលេខ ២២៣០ អយក.ត ចុះថ្ងៃទី ១៣ មិថុនា ១៩៩៦
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

សម្រេច

ប្រការ ១ :អនុញ្ញាតិអោយមន្ទីរអប់រំយុវជន និង កីឡា ខេត្តតាកែវ ប្តូរឈ្មោះសាលា បឋមសិក្សា « ព្រៃជ្វរ » ស្ថិតក្នុងឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ មកជាសាលាបឋមសិក្សា « **ហ៊ុន សែន_ព្រៃជ្វរ** » វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៦_១៩៩៧ នេះតទៅ ។

ប្រការ ២ :បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៣ :ប្រធានមន្ទីរ ក្រសួងអប់រំយុវជន និង កីឡា ប្រធាននាយកដ្ឋានបាត់ពាំង ប្រធាននាយកដ្ឋានផែនការ_ហិរញ្ញកិច្ចប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

ប្រធាន មន្ទីរអប់រំយុវជន និង កីឡា ខេត្តតាកែវ ប្រធានការិយាល័យអប់រំយុវជន និង កីឡា ស្រុកត្រាំកក់ នាយកសាលាបឋមសិក្សា « **ហ៊ុន សែន_ទ្រាំងួរ** » មានភារកិច្ចអនុវត្ត ប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

គា សាហាន

* * *

ភ្នំពេញ,ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៩១៧ អយក.ប្រក

ស្តីពីការប្តូរឈ្មោះវិទ្យាល័យពាមជីកង ទៅជាវិទ្យាល័យ

សម្តេច ហ៊ុន សែន «ពាមជីកង» ស្ថិតក្នុងស្រុកកងមាស

ខេត្តកំពង់ចាម

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦ កក្កដា ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ ឆ្នាំ
- យោងលិខិតស្នើរបស់គណៈកម្មការទ្រទ្រង់វិទ្យាល័យពាមជីកង ចុះថ្ងៃទី ០៧ ឧសភា ១៩៩៦ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំយុវជន និង កីឡា និងអភិបាលខេត្តកំពង់ចាម
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយប្តូរឈ្មោះវិទ្យាល័យពាមជីកង បច្ចុប្បន្នទៅជាវិទ្យាល័យ សម្តេច **ហ៊ុន សែន** « ពាមជីកង » ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ២ : វិទ្យាល័យនេះ ត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេង ៗ ទៀតមួយចំនួនតាមអង្គការលេខ នៃ វិទ្យាល័យ ។

ប្រការ ៣ : នាយក_នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចរបស់នាយក_នាយក រងនៃវិទ្យាល័យ ។

ប្រការ ៤ : បទបញ្ញត្តទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៥ :ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅនិងមត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិកប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជននិងកីឡាប្រធានមន្ទីរអប់រំយុវជននិងកីឡាខេត្តកំពង់ចាម និងនាយកវិទ្យាល័យសាមីមានភារកិច្ចរៀង ៗ ខ្លួនអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា
រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
គា សាហាន

* * *

ភ្នំពេញ,ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៨៦

ប្រកាសលេខ ៩១៨ អយក.ប្រក

ស្តីពីការប្តូរឈ្មោះវិទ្យាល័យអន្លង់វ៉ែង ទៅជាវិទ្យាល័យ សម្តេច ជា ស៊ីម «អន្លង់វ៉ែង» ស្ថិតក្នុងស្រុកអន្លង់វ៉ែង ខេត្តកំពត

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

_បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន**

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤

_បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ ឆ្នាំ

_យោងលិខិតស្នើរបស់គណៈកម្មការទ្រទ្រង់វិទ្យាល័យអង្គរជ័យ ចុះថ្ងៃទី២៥ឧសភា ១៩៩៦ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំយុវជន និង កីឡា និងអភិបាលខេត្តកំពត

_តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយប្តូរឈ្មោះវិទ្យាល័យអង្គរជ័យ បច្ចុប្បន្នទៅជាវិទ្យាល័យសម្តេច **ជា ស៊ីម** « អង្គរជ័យ » ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ២ : វិទ្យាល័យនេះ ត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំង បុគ្គលិកផ្សេង ។ ទៀតមួយចំនួនតាមអង្គការលេខនៃវិទ្យាល័យ ។

ប្រការ ៣ : នាយក _ នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចរបស់នាយក _ នាយករងនៃវិទ្យាល័យ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៥ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅនិងមត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការនិងហិរញ្ញកិច្ច នៃ ក្រសួងអប់រំយុវជននិងកីឡា_ ប្រធានមន្ទីរអប់រំយុវជននិងកីឡាខេត្តកំពត និងនាយកវិទ្យាល័យសាមីមានភារកិច្ចរៀង។ ខ្លួនអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

គា សាមាន

ភ្នំពេញ,ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៩១៩ អយក.ប្រក

ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យខ្មៅ ទៅជាអនុវិទ្យាល័យ

សម្តេច ហ៊ុន សែន « ខ្មៅ » ស្ថិតក្នុងស្រុកកងមាស

ខេត្តកំពង់ចាម

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាស អោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦ កក្កដា ស្តីពី ប្រព័ន្ធអប់រំចំណេះទូទៅ ១២ ឆ្នាំ
- យោងលិខិតស្នើរបស់គណៈកម្មការទ្រទ្រង់អនុវិទ្យាល័យខ្មៅ ចុះថ្ងៃទី ១៥ មេសា ១៩៩៦ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំយុវជន និង កីឡា និងអភិបាល ខេត្តកំពង់ចាម
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ :អនុញ្ញាតអោយប្តូរឈ្មោះអនុវិទ្យាល័យខ្មៅ បច្ចុប្បន្នទៅជាអនុវិទ្យាវិទ្យាល័យ **ហ៊ុន សែន** «ខ្មៅ» ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ២ :អនុវិទ្យាល័យនេះ ត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រម ទាំង បុគ្គលិកផ្សេង ។ ទៀតមួយចំនួនតាមអង្គការលេខ នៃ អនុវិទ្យាល័យ ។

ប្រការ ៣ :នាយក _ នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចរបស់ នាយក _ នាយករងនៃអនុវិទ្យាល័យ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

